# ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Mar-2013, 15:28
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំពិចារណាភស្តុតាងបន្ថែម

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្តី នួន ជា**

Victor KOPPE
Joshua ROSESWEIG
Forest O'NEILL-GREENBERG
Renee DE GEUS
Mateusz GAWALKIEWICZ

<u>**ផ្ញើជូន៖**</u>

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

អនុលោមតាមវិធាន ១០៤(១) និងវិធាន១០៨(៧) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះ សូមដាក់សំណើ សុំពិចារណាភស្តុតាងបន្ថែម ("សំណើសុំពិចារណាភស្តុតាងបន្ថែម") ពាក់ព័ន្ធនឹងបណ្តឹងសារទុក្ខភ្លាមដែលមិនទាន់ដោះស្រាយនៅឡើយ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន៣៥ ។

## I. ប្រវត្តិនីតិវិធី

១. ជាការឆ្លើយតបចំពោះការលាឈប់ពីមុខតំណែងរបស់សហចៅក្រមស៊ើបអង្កេត Laurent Kasper-Ansermet ("សំណើដើម")[1] នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី ដាក់សំណើដោយអនុលោមតាមវិធាន ៣៥ ។ នៅក្នុងសំណើដើមនេះ មេធាវីការពារក្តីបានលើកអំណះអំណាងថា ការលាឈប់របស់ចៅក្រមស៊ើបអង្កេត Laurent Kasper-Ansermet គឺជាតឹកតាងបន្ថែមពីកម្រិតនៃការជ្រៀតជ្រែកខាងនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលកំពុងធ្វើប៉ះពាល់ដល់ដំណើរការនិតីវិធីនៅក្នុងករណីទាំងអស់នៅ អវតក។ អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំឱ្យមានការស៊ើបអង្កេតពេញលេញទៅលើឥទ្ធិពលនៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលទៅលើភាពត្រឹមត្រូវនៃករណី00២ និងសុំផ្អាកកិច្ចដំណើរការនីតិវិធីដោយរង់ចាំលទ្ធផលនៃការស៊ើបអង្កេតពេញលេញសិន[2]។

២. អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចនៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដោយបានបដិសេធដំណោះស្រាយទាំងអស់ដែលបានស្នើឡើងនៅក្នុងសំណើដើម ("សេចក្តីសម្រេចដែលរងការជំទាស់")[3]។ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់បណ្តឹង

---

[1] សូមមើលឯកសារ E-189 "សំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន៣៥" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ERN 00803004-00803019 ("សំណើដើម")។

[2] សំណើដើម នៅកថាខណ្ឌទី២៨ ។

[3] ឯកសារ E-189/3 "សេចក្តីសម្រេចលើសំណើ សុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន៣៥" ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ ERN 00859224-00859231 ("សេចក្តីសម្រេចដែលរងការជំទាស់")។

សារទុក្ខភ្ជាមប្រឆាំងនឹងសេចក្តីសម្រេចនោះ ("បណ្តឹងសារទុក្ខភ្ជាម")[4]។ នៅថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាដាក់សារណាឆ្លើយតប[5] ហើយនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ មេធាវីការពារក្តីដាក់ចម្លើយតប[6]។

៣. នៅខែ មករាឆ្នាំ ២០១៣ អតីតសហចៅក្រមស៊ើបអង្កេត Marcel Lemonde បានចេញផ្សាយសៀវភៅមួយក្បាលមានចំណងជើងថា *Un Juge Face Aux Khmer Rouges* ("សៀវភៅ Lemonde")។ សៀវភៅ Lemonde គឺជាសេចក្តីសង្ខេបដែលមានលក្ខណៈទូលំទូលាយពីបទពិសោធន៍របស់ចៅក្រម Lemonde នៅ អវតក។ មានសេចក្តីថ្លែងជាច្រើននៅក្នុងសៀវភៅនេះ បង្ហាញនូវព្រឹត្តិហេតុជាច្រើន ដែលមេធាវីការពារក្តីមិនបានដឹងកាលពីពេលមុន ដែលប៉ះពាល់ដោយផ្ទាល់លើការសម្រេចរបស់អង្គជំនុំជម្រះលើបណ្តឹងសារទុក្ខនេះ។ អាស្រ័យហេតុនេះ មេធាវីការពារក្តី ស្នើសុំដាក់សេចក្តីថ្លែងទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងស្នើសុំឲ្យពិចារណាថា សេចក្តីថ្លែងទាំងនេះពាក់ព័ន្ធនឹងគោលបំណងដែលបានបញ្ជាក់នៅក្នុងសំណើនេះ។ សម្រង់ច្បាប់ដើមជាភាសាបារាំង ដែលពាក់ព័ន្ធត្រូវបានដាក់ភ្ជាប់មកជាមួយ[7]។

## II. សៀវភៅ LEMONDE

---

[4] ឯកសារ E-189/3/1/1 "បណ្តឹងសាទុក្ខភ្ជាមប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ ERN 00872601-00872631 ("បណ្តឹងសាទុក្ខភ្ជាម")។

[5] ឯកសារ E-189/3/1/2 "សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសារទុក្ខភ្ជាមរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥" ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ ERN 00878190-00878208 ។

[6] ឯកសារ E-189/3/1/3 "ចម្លើយទៅនឹងសារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងសារទុក្ខភ្ជាមដោយអនុលោមតាមវិធាន៣៥" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ERN 00880941-00880947 ។

[7] សម្រង់សំខាន់បំផុតពីសៀភៅ Lemonde ត្រូវបានចម្លងឡើងវិញទាំងស្រុងនៅក្នុងសំណើនេះ និងត្រូវបានបកប្រែជាបីភាសាសម្រាប់គោលបំណងនេះ។ សម្រង់ដែលមេធាវីការពារក្តីចង់លើកមកសំអាងដែលដាក់ភ្ជាប់ជាមួយសំណើនេះគឺមានតែជាភាសាបារាំង ដោយសារតែក្នុងពេលបច្ចុប្បន្ននេះ មិនមានអ្នកបកប្រែពីភាសាបារាំងទៅភាសាខ្មែរ។

៤. សៀវភៅ Lemonde មានកម្រាស់ ២៤៣ ទំព័រ គឺជាការពន្យល់ដំបូងបំផុតអំពីរឿងរ៉ាវរបស់ចៅក្រម Lemonde នៅ អវតក។ សៀវភៅនេះរៀបរាប់អំពីកិច្ចការរបស់ចៅក្រម Lemonde នៅក្នុងសំណុំរឿង ០០១ ០០២ និង ០០៣ ហើយជាញឹកញាប់និយាយយោងអំពីអន្តរកម្មរបស់គាត់ជាមួយចៅក្រម បុគ្គលិក និងអ្នកនយោបាយកម្ពុជា។ ការយោងជាច្រើនក្នុងចំណោមការយោងទាំងនេះ គាំទ្រការអះអាងដែលមានយូរមកហើយរបស់ក្រុមមេធាវីការពារក្តី រួមទាំងការអះអាងនៅក្នុងសំណើដើម និងបណ្តឹងសារទុក្ខភ្លាមនេះទាក់ទងនឹងការគ្មានឯករាជ្យខាងតុលាការពេញលេញនៅអវតក។ ខាងក្រោមនេះគឺជាសម្រង់ច្បាប់ដើមជាភាសាបារាំងដែលពាក់ព័ន្ធ:

a. Il est évident que, derrière les juges cambodgiens, il y a des gens qui tirent les ficelles au sein de gouvernement. (p. 32)

b. Je comprendrai bien plus tard qu'en réalité ils avaient une longueur d'avance sur nous, anticipant sur la possibilité de bloquer des poursuites jugées politiquement inopportunes. (pp. 37-38)

c. Avec le recul, je ne suis pas certain que le gouvernement cambodgien ait eu en tête un plan murement réfléchi. Plus vraisemblablement, les dirigeants s'en tenaient à un raisonnement qu'ils connaissaient bien, fort simple: quel mal y a-t-il à changer un juge puisque, de toute façon, un juge est là pour exécuter les ordres? (p. 50)

d. Dans ce contexte troublé, j'eus aussi l'occasion de recevoir le soutien d'un autre juge cambodgien, qui me toucha en ce qu'il était révélateur d'une marque de confiance considérable de la part de ce magistrat. Il m'expliqua sans détour qu'en fait le gouvernement n'attendait qu'une chose, me voir partir: je ne pouvais que déranger, avec mes réactions par trop différentes de celles auxquelles il était habitué, de la part des diplomates ou des politiques. Poursuivant sa description de la société locale, ce juge ajouta que je devais me méfier de tous les magistrats cambodgiens: ou bien ils vivaient dans la peur du pouvoir en place ou bien ils en étaient proches mais, dans tous les cas, aucun n'était fiable ni indépendant. Pendent tout mon séjour au Cambodge, ce fut la seule fois où l'on me parla aussi franchement. (p. 51)

e. Du coté des intéressés, aucune réponse. Je demande au greffier de repartir à la charge par téléphone et de noter toutes ses conversations. Il est « baladé » de service en service et de numéro absent en numéro incorrect pendant plusieurs semaines. Quand il parvient à joindre un correspondant, celui-ci lui dit généralement qu'il va en référer a l'échelon supérieur, promettant de rappeler, ce qu'il va ne fait jamais. Seul le directeur de

cabinet de l'une des personnes convoquées se risque un jour à aborder le fond, déclarant tout de go qu'on ne peut pas convoquer ainsi un haut dirigeant, car cela pourrait nuire à sa carrière politique ! You Bunleng demandera discrètement si ce membre de phrase est vraiment indispensable dans le compte rendu...Pour lui faire plaisir, on effacera la malheureuse expression : comme toujours, il faut bien mettre un peu d'huile dans les rouages, si l'on veut ne pas trop compromettre l'avenir. (p. 176)

f. Quelques mois plus tard, Hor Namhong reviendra sur le sujet, justifiant son refus de témoigner par de pseudo-considérations juridiques, n'hésitant pas à expliquer, lors d'une conférence de presse, que j'avais « violé la loi » en signant seul les convocations :

- Selon les règles établies entre le Cambodge et les Nations Unies, il doit y avoir deux signatures, coté cambodgien et coté international.

Je répondis simplement qu'un juge n'avait pas à polémiquer avec un témoin. Les medias locaux ne furent évidemment pas dupes et confirmèrent le manque de sérieux de l'argument avance. Cependant, une telle mauvaise foi de la part d'un membre du gouvernement ne laissait pas d'inquiéter : en l'absence de réaction, la liberté d'action des juges internationaux risquait à l' avenir d'être directement menacée. Nous en parlâmes entre nous et, estimât que les déclarations du ministre soulevaient un sérieux problème de principe, nous décidâmes d'en saisir les Nations unies.

Au nom de tous les juges internationaux, Silvia Cartwright envoya donc une lettre à Patricia O'Brien, la conseillère juridique de l'ONU. La réponse qui nous parvint fut décevante ; en résume, notre interlocutrice « partageaient nos préoccupations », mais elle relevait, avec satisfaction, que les commentaires qui avaient suivi les propos du ministre avaient rétabli les faits. Il n'y avait donc pas lieu d'aller plus loin. D'ailleurs, le vice-Premier ministre Sok An n'avait-il pas récemment confirme que le gouvernement soutenait et respectait l'indépendance des CETC ? En somme, il n'y avait pas lieu de s'inquiéter.

Nous dûmes nous contenter de ce « soutien ». (pp. 179-180)

៥. សម្រង់ដូចគ្នានេះត្រូវបានបកប្រែដូចខាងក្រោម:

ក. វាច្បាស់ណាស់ថា ខាងក្រោយខ្នងចៅក្រមកម្ពុជាមានអ្នកញាក់ខ្សែរចេញពីក្នុងរដ្ឋាភិបាល (ទំព័រ៣២)។

ខ. ខ្ញុំទើបតែដឹងនៅពេលក្រោយៗមកថា ពួកគេលឿនជាងយើងមួយជំហាន ដោយសារពួកគេកំពុងតែរៀបចំសម្រាប់ការរារាំងនូវកិច្ចដំណើរការនីតិវិធីណាដែលត្រូវបានគេចាត់ទុកថា ជាការអាម៉ាស់ខាងនយោបាយ (ទំព័រ៣៧-៣៨)។

គ. នៅក្នុងការយល់ឃើញពេលក្រោយៗមក ខ្ញុំមានមន្ទិលសង្ស័យរដ្ឋាភិបាលកម្ពុជាមានផែនការគិតទុកជាមុនយ៉ាងច្បាស់លាស់។ មេដឹកនាំប្រហែលជាតាមដានរាល់ហេតុផលដែលគេដឹងច្បាស់ មិនថាជាមូលហេតុសាមញ្ញ ឬហេតុផលដែលល្អឥតខ្ចោះនោះទេ: តើមានបញ្ហាអ្វីបើមានការប្តូរចៅក្រមមែន ក្នុងករណីណាក៏ដោយ ឲ្យតែចៅក្រមហ្នឹងត្រូវតែធ្វើតាមការបញ្ជា?(ទំព័រ៥០)។

ឃ. នៅក្នុងស្ថានភាពដ៏លំបាកនេះ ខ្ញុំទទួលបានការគាំទ្រពីចៅក្រមកម្ពុជាម្នាក់ដែលផ្តល់កំលាំងចិត្តដល់ខ្ញុំ ដោយសារគាត់បង្ហាញឲ្យខ្ញុំឃើញនូវទំនុកចិត្តដ៏ច្រើនលើគាត់។ ដោយមិននិយាយវែងឆ្ងាយ គាត់ពន្យល់ថារដ្ឋាភិបាលកំពុងតែរង់ចាំមើលរឿងតែមួយគត់ ដែលនោះគឺការចាកចេញរបស់ខ្ញុំ។ ប្រតិកម្មរបស់ខ្ញុំដែលខុសគ្នាយ៉ាងស្រឡះពីប្រតិកម្មនានាដែលធ្លាប់ទទួលបានពីអ្នកការទូត ឬអ្នកនយោបាយ ខ្ញុំជាមនុស្សតែម្នាក់គត់ដែលបង្កើតបញ្ហា។ ខណៈដែលគាត់បរិយាយបន្តអំពីសង្គមកម្ពុជា ចៅក្រមម្នាក់នេះបន្ថែមថា ខ្ញុំត្រូវតែប្រយ័ត្នប្រយែងជាមួយចៅក្រមកម្ពុជាទាំងអស់: មិនថាឡើយពួកគេរស់នៅជាមួយការភ័យខ្លាចពីស្ថាប័ននយោបាយ ឬពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយស្ថាប័ននយោបាយនោះទេ តែពួកគេមិនអាចឲ្យជឿទុកចិត្តបាន ហើយក៏មិនឯករាជ្យដែរ។ នេះគឺជាពេលវេលាតែមួយគត់នៅក្នុងកំឡុងពេលនៃការស្នាក់នៅរបស់ខ្ញុំនៅប្រទេសកម្ពុជា ដែលមានមនុស្សនិយាយជាមួយខ្ញុំយ៉ាងស្មោះត្រង់បែបនេះ។

ង. ពុំមានការឆ្លើយតបពីភាគីម្ខាងទៀតទេ។ ខ្ញុំប្រាប់ក្រឡាបញ្ជីឲ្យទូរស័ព្ទ និងកត់ត្រាអំពីការសន្ទនាទាំងអស់របស់គាត់។ អស់ពេលជាច្រើនសប្តាហ៍ ក្រឡាបញ្ជីចេញពីការិយាល័យមួយទៅការិយាមួយ "ទូរស័ព្ទទៅគេ គេមិនលើក" ឬទូរស័ព្ទចូលហើយ "ចូលលេខមិនត្រឹមត្រូវ"។ នៅពេលដែលក្រឡាបញ្ជីទូរស័ព្ទចូលនរណាម្នាក់ គាត់តែងតែត្រូវបានគេប្រាប់ថាបញ្ហានឹងបញ្ជូនទៅថ្នាក់លើ ហើយគេសន្យាថានឹងទូរស័ព្ទមកគាត់វិញ ដែលករណីនេះមិនដែលកើតឡើងឡើយ។ មានតែ

ប្រធានខុទ្ទកាល័យរបស់មនុស្សម្នាក់ដែលត្រូវបានកោះហៅ ប៉ានប្រថុយជជែកស៊ីជម្រៅលើបញ្ហាពិត ជាពិសេសចំពោះមន្ត្រីជាន់ខ្ពស់បែបនេះ គេមិនអាចត្រូវបានកោះហៅទេ ព្រោះអាចប៉ះពាល់ដល់អាជីពនយោបាយរបស់គាត់។ ចៅក្រម យូ ប៊ុនឡេង បានស្នើសុំដោយស្ងាត់ៗថា តើវាជាការចាំបាច់ពិតប្រាកដមែនឬទេ ដើម្បីបញ្ចូលការអធិប្បាយនេះនៅក្នុងរបាយការណ៍...។ ដើម្បីបំពេញចិត្តគាត់ ការអធិប្បាយនេះត្រូវបានដកចេញ។ ជាធម្មតា វាជាការចាំបាច់ដើម្បីសម្រួលកុំឱ្យស្ថានការណ៍កាន់តែអាក្រក់ជាងនេះ (នៅទំព័រ១៧៦)

ច. ពីរបីខែក្រោយមក ហោ ណាំហុង ត្រឡប់មកពិភាក្សាលើបញ្ហានេះដោយបានផ្តល់យុត្តិកម្មអំពីការបដិសេធរបស់គាត់មិនផ្តល់សក្ខីកម្ម ជាមួយនឹងអំណះអំណាងផ្នែកច្បាប់មិនស្មោះត្រង់ និងបានថ្លែងដោយមិនបានបម្រុងទុកជាមុននៅសន្និសិទ្ធសារព័ត៌មានថា ខ្ញុំបាន "បំពានច្បាប់" តាមរយៈចុះហត្ថលេខាតែម្នាក់ឯងលើដីកាកោះហៅ:

- អនុលោមវិធានដែលបង្កើតឡើងដោយកម្ពុជា និងអង្គការសហប្រជាជាតិ ចាំបាច់មានហត្ថលេខាពីរ: ហត្ថលេខាមួយពីកម្ពុជា និងហត្ថលេខាមួយទៀតពីភាគីអង្គការសហប្រជាជាតិ។

ខ្ញុំឆ្លើយតបដោយសាមញ្ញថា វាមិនមានប្រយោជន៍ចំពោះចៅក្រមក្នុងការជជែកវែកញែកជាសាធារណៈជាមួយសាក្សី។ ពិតណាស់សារព័ត៌មានក្នុងស្រុកពុំភាន់ច្រឡំទេ និងបានរាយការណ៍ថាអំណះអំណាងនេះពុំមានអត្ថន័យសំខាន់។ ប៉ុន្តែការមិនមានភាពស្មោះត្រង់នៃមន្ត្រីរដ្ឋាភិបាលម្នាក់ បង្កនូវភាពច្របូកច្របល់: នៅពេលគ្មានប្រតិបត្តិតបណាមួយ សេរីភាពនៃការធ្វើកិច្ចការរបស់ចៅក្រមអន្តរជាតិអាចប៉ះពាល់ដោយផ្ទាល់នៅអនាគត។ យើងលើកយកបញ្ហានេះមកពិភាក្សាក្នុងចំណោមពួកយើង និងបានសម្រេចបញ្ជូនបញ្ហានេះទៅអង្គការសហប្រជាជាតិ ដោយសារតែយើងយល់ថា ការថ្លែងរបស់រដ្ឋមន្ត្រីរូបនេះលើកឡើងនូវបញ្ហាសិលធម៌ជាមូលដ្ឋាន។

ដូច្នេះចៅក្រម Silvia Cartwright ក្នុងនាមចៅក្រមអន្តរជាតិទាំងអស់បញ្ជូនលិខិតមួយច្បាប់ទៅអ្នកស្រី Patricia O'Brien ទីប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិ។ ចម្លើយរបស់គាត់ធ្វើឱ្យយើងខកចិត្ត។ អ្នកស្រី Patricia O'Brien និយាយយ៉ាងខ្លីថា "គាត់ចែករំលែកក្តីបារម្ភរបស់យើង" ប៉ុន្តែបានកត់សម្គាល់ជាមួយនឹងការពេញចិត្តថា ការអធិប្បាយនានាក្រោយពីការថ្លែងរបស់រដ្ឋមន្ត្រីបានបភ្លឺពីអង្គហេតុ។ ហេតុដូច្នេះវាមិនចាំចាច់ឲ្យបញ្ហាវែងឆ្ងាយតទៅទៀតទេ។ តាមពិតបើឧបនាយករដ្ឋមន្ត្រី សុខ អាន មិនបានបញ្ជាក់នាពេលថ្មីៗនេះថារដ្ឋាភិបាលគាំទ្រ និងគោរពឯករាជ្យរបស់ អវតក? បើសិនជាអ្វីៗទាំងអស់ដែលបាននិយាយ ហើយបានធ្វើមែន នោះវានឹងមិនមានអ្វីដែលត្រូវព្រួយបារម្ភរណ៍ទេ។

យើងត្រូវតែទទួលយកនូវ "ការគាំទ្រ" នេះប៉ុណ្ណោះ ។ (ទំព័រ១៧៩-១៨០)

## III. ច្បាប់ដែលត្រូវអនុវត្ត

### ក. ការទទួលយកភស្តុតាងថ្មីនៅបណ្តឹងសារទុក្ខ

៦. នៅក្នុងក្របខណ្ឌរបស់ អវតក ការទទួលយកភស្តុតាងថ្មីនៅបណ្តឹងសារទុក្ខ មានចែងនៅក្នុងវិធាន១០៤(១) និងវិធាន១០៨(៧) ។ អនុលោមតាមវិធាន ១០៤(១) អង្គជំនុំជម្រះតុលាការកំពូល "ខ្លួនឯងអាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី" ។ វិធាន១០៨(៧) ចែងនៅផ្នែកពាក់ព័ន្ធដូចខាងក្រោម:

> ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន៨៧(៣) បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ ។ សេចក្តីស្នើសុំបន្ថែមភស្តុតាង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់ រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង ។

៧. អង្គជំនុំជម្រះនេះកាលពីលើកមុនបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបន្ថែមភស្តុតាងថ្មី ដោយអនុលោមតាមវិធាន១០៨(៧)[8]។ វិធានស្រដៀងគ្នាត្រូវបានយកមកអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ICTR[9]។

## ខ. ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ

៨. មេធាវីការពារក្តីដាក់បញ្ចូលគោលការណ៍នានាដែលអនុវត្តចំពោះវិធាន៣៥ ដែលត្រូវបានយកមកសំអាងនៅក្នុងសំណើដើម និងបណ្តឹងសារទុក្ខ។

## IV. អំណះអំណាង

## ក. សំណើសុំបន្ថែមភស្តុតាងនេះ អាចទទួលយកបាន

៩. វិធាន១០៤(១) អនុញ្ញាតឲ្យអង្គជំនុំជម្រះនេះពិចារណាភស្តុតាងថ្មីនៅបណ្តឹងសារទុក្ខ ។ វិធាន១០៨(៧) មានបំណងយ៉ាងច្បាស់សំណើសុំបន្ថែមភស្តុតាងបែបនេះ ត្រូវតែបានទទួលយកដោយពុំមានលក្ខខណ្ឌ។ ហេតុដូច្នេះ សំណើនេះអាចទទួលយកបាន ។

## ខ. សៀវភៅ Lemonde មិនអាចរកបាននៅពេលសវនាការ

១០. សៀវភៅ Lemonde ត្រូវបានបោះពុម្ពផ្សាយនាខែ មករា ឆ្នាំ ២០១៣ ក្រោយពីការដាក់សំណើដើម សេចក្តីសម្រេចដែលរងការជំទាស់ និងបណ្តឹងសារទុក្ខភ្លាម។ អង្គហេតុដែលពាក់ព័ន្ធរួមបញ្ចូលទាំងទស្សនៈផ្ទាល់ និងអន្តរកម្មរបស់ចៅក្រម Lemonde ព្រមទាំងព័ត៌មានដទៃទៀតដែលមិនអាចរកបានជាសាធារណៈពីមុន ហើយថែមទាំងមិនបានមកដល់ដៃមេធាវីការពារក្តីនៅមុនការបោះពុម្ពផ្សាយសៀវភៅនេះទេ។ បើទោះបីជាគ្មានលក្ខខណ្ឌតម្រូវបន្ថែមពីពេល

---

[8] ករណី០០១/១៨-០៧-២០០៧-អវតក-អជតក, សហព្រះរាជអាជ្ញា តទល់ កាំង ហ្គេកអ៊ាវ ហៅ ឌុច, ឯកសារ F-2/5/1 សេចក្តីសម្រេចលើសំណើបន្ថែមភស្តុតាងរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំបន្ថែមភស្តុតាង" ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១១ ERN 00657389-00657391 ។ ករណី០០១/១៨-០៧-២០០៧-អវតក-អជតក, សហព្រះរាជអាជ្ញា តទល់ កាំង ហ្គេកអ៊ាវ ហៅ ឌុច, ឯកសារ F-2/4 "សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារជនជាប់ចោទ និងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម២ និងក្រុម សុំបន្ថែមភស្តុតាង" ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១១ ERN 00656514-00656517។

[9] ករណីរដ្ឋអាជ្ញា តទល់ *Semanza*, ICTR-97-20-A, ' សេចក្តីសម្រេច" ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០។

វេលានៅក្នុងវិធាន១០៨(៧) មេធាវីការពារកត់សម្គាល់ថាសៀវភៅនេះត្រូវបានបោះពុម្ពផ្សាយនៅប្រទេសបារាំង ហើយទើបតែអាចរកបាននៅទីក្រុងភ្នំពេញនាពេលថ្មីៗនេះ។ ម្យ៉ាងទៀត សៀវភៅនេះត្រូវបានសរសេរឡើងជាភាសាបារាំង ហើយតម្រូវឲ្យមានការពិនិត្យយ៉ាងល្អិតល្អន់ ថ្វីបើក្រុមមេធាវីការពារក្តី នួន ជា ខ្វះសមត្ថភាពខាងភាសាបារាំង ។ សម្រាប់ហេតុផលទាំងនេះសំណើនេះត្រូវបានដាក់ឆាប់បំផុត តាមដែលអាចធ្វើទៅបាន។

## គ. សៀវភៅ Lemonde បង្កើតមូលហេតុបន្ថែមទៀតដើម្បីឲ្យជឿជាក់ថាមន្ត្រីរដ្ឋាភិបាលបានជ្រៀតជ្រែក និងបន្តជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ

១១. សេចក្តីសម្រេចដែលរងការជំទាស់យល់ឃើញថា សំណើដើមខកខានមិនបាន "កំណត់ផលប៉ះពាល់ជាក់ស្តែងណាមួយ ដែលបានចោទប្រកាន់ទៅលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំម្រះក្តីនៅក្នុងករណី០០២នោះទេ[10]។ បណ្តឹងសារទុក្ខភ្លាមផ្តល់មូហេតុដាច់ដោយឡែកពីគ្នាយ៉ាងតិចប្រាំដែរ ទាក់ទងនឹងអ្វីដែលថា ការសន្និដ្ឋាននេះមានកំហុស[11]។ សៀវភៅ Lemonde ផ្តល់ភស្តុតាងគាំទ្រសំខាន់ទាក់ទងនឹងចំណុចនេះ ហើយហេតុដូច្នេះ "វាអាចជាកត្តាដ៏សំខាន់ក្នុងការធ្វើសេចក្តីសម្រេចនៅសវនាការ"។

### i. ចៅក្រមកម្ពុជាមិនអាចបំពេញតួនាទីដោយឯករាជ្យបានទេនៅក្នុងករណី០០២

១២. ផ្ទុយពីការប្រកាសជាសាធារណៈរបស់ខ្លួន សៀវភៅ Lemonde បង្កើតមូលហេតុថារាជរដ្ឋាបាលកម្ពុជាមិនគោរព ហើយមិនដែលបានគោរពឯករាជ្យរបស់ អវតក ទេ។ មានពេលមួយ តួនី ក្រាញ់ ប្រធានការិយាល័យរដ្ឋបាលស្តីទី ព្រមានចៅក្រម Lemonde:

> Votre attitude risque de donner des arguments à ceux qui, dans les hautes sphères, pensent qu'on a déclenché une machine infernale avec ce procès *qu'on n'arrive plus à contrôle[12]r.* (បញ្ជាក់បន្ថែម)

---

[10] សេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ១០ ។

[11] បណ្តឹងសារទុក្ខភ្លាម នៅកថាខណ្ឌ២៥-៥១ ។

[12] សៀវភៅ Lemonde ទំព័រ១៧៧ ។

នៅក្នុងបរិបទនេះអាកប្បកិរិយានេះប៉ះពាល់ដល់កិច្ចប្រឹងប្រែងរបស់ចៅក្រម Lemonde ដើម្បីឱ្យផ្នែក CMS អនុវត្តដីកាឱ្យចំណាត់ថ្នាក់ឯកសារឡើងវិញដ៏សាមញ្ញមួយប្រឆាំងនឹងបំណងរបស់ចៅក្រម ប៊ុនឡេង និងរាជរដ្ឋាភិបាលកម្ពុជា[13]។ ក្បាលម៉ាស៊ីនដ៏អាក្រក់ 'machine infernale' មានមុខងារតុលាការឯករាជ្យមួយដែលរដ្ឋាភិបាលមិនអាចត្រួតពិនិត្យបានទេ (government 'n'arrive plus à contrôler) ។ គោលដៅនៃការត្រួតពិនិត្យនេះ-កិច្ចដំណើរការនិតីវិធី 'ce procès' – មិនមែនករណី ០០៣ ឬ ០០៤ តែជាករណី ០០២។ ប្រភពនៃការព្រមាននេះ គឺពីមន្ត្រីជាន់ខ្ពស់បំផុតនៅ អវតក ហើយបុគ្គលនេះទទួលខុសត្រូវដោយផ្ទាល់ក្នុងការរាយការណ៍ទៅរដ្ឋាភិបាលកម្ពុជា។ ជាសន្និដ្ឋាន មិនអាចជៀសបានរាជរដ្ឋាភិបាលកម្ពុជាមានចេតនាពេញលេញក្នុងការត្រួតត្រាកិច្ចដំណើរការនិតីវិធីនៅក្នុងករណី០០២ ។

១៣. ផ្អែកលើបទពិសោធន៍ជាងបួនឆ្នាំរបស់គាត់ក្នុងការដោះស្រាយបញ្ហានយោបាយដ៏រសើប និងការធ្វើអន្តរកម្មប្រចាំថ្ងៃជាមួយសមាសភាគីកម្ពុជារបស់គាត់ ចៅក្រម Lemonde បញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជាមានសមត្ថភាពយ៉ាងពេញលេញក្នុងការអនុវត្តគោលបំណងនេះ។ អនុលោមតាមចៅក្រម Lemonde រដ្ឋាភិបាល "កំពុងតែញាក់ខ្សែ" ពីខាងក្រោយខ្នងចៅក្រមកម្ពុជានៅ អវតក និងរំពឹងយ៉ាងមុតមាំថាចៅក្រមទាំងនោះ "ធ្វើតាមការបញ្ជា" ដោយស្មោះស្ម័គ្រ។ ចៅក្រម Lemonde មានអារម្មណ៍ថា ដំបូន្មាន "ដ៏ស្មោះត្រង់" ដែលគាត់ទទួលអំពីប្រព័ន្ធតុលាការកម្ពុជាក្នុងកំឡុងពេលបួនឆ្នាំនៅកម្ពុជា គឺថាពុំមានចៅក្រមកម្ពុជាណាម្នាក់ដែលឯករាជ្យ ឬគួរឱ្យជឿទុកចិត្តបានឡើយ ដោយសារពួកគេភ័យខ្លាច ឬនៅជិតក្បែរនឹងអំណាច។

១៤. ខុសគ្នាពីចៅក្រម Kasper-Ansermet បទពិសោធន៍របស់ចៅក្រម Lemonde ទាក់ទងនឹងបញ្ហានេះមិនអាចលាក់នៅខាងក្រោយវាំងននៃសំណុំរឿង ០០៣ និង ០០៤ បានទេ។ ជាការពិតចៅក្រម Lemonde ពាក់ព័ន្ធស្ទើរតែទាំងស្រុងនៅក្នុង សំណុំរឿង ០០១ និង ០០២ ជាមួយនឹងការបញ្ចេញ ពន្លឺមានកម្រិតដល់សំណុំរឿង ០០៣[14]។ តែចៅក្រម Lemonde មិនបាន

---

[13] សូមមើលកថាខណ្ឌ១៦ ខាងក្រោម ។

[14] ករណី០០៣ មិនមានរូបរាងរហូតដល់១៤ខែចុងក្រោយនៃអាណត្តិការងារជាងបួនឆ្នាំកន្លះរបស់ចៅក្រម Lemonde នៅ អវតក។ រវាងខែកញ្ញាឆ្នាំ២០០៩ នៅពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរនៅក្នុងករណី០០៣ ត្រូវបានចេញ

ប្រឹងប្រែងដើម្បីកម្រិតវិសាលភាពនៃការសន្និដ្ឋានរបស់គាត់ ទាក់ទងនឹងឥទ្ធិពលរបស់រាជរដ្ឋាភិបាលកម្ពុជានោះទេ កុំថាឡើយទស្សនៈវិស័យសំខាន់នៃកិច្ចការរបស់គាត់នៅតុលាការ[15]។ ហេតុដូច្នេះទស្សនៈទូទៅរបស់គាត់ដែលថា ចៅក្រមជាតិទាំងអស់ដែលទទួលសំពាធពីរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបានទាញចេញពីបទពិសោធន៍របស់គាត់នៅក្នុងសំណុំរឿង០០១ និង ០០២។

### ii. រាជរដ្ឋាបាលកម្ពុជាជ្រៀតជ្រែកដោយខុសច្បាប់នៅក្នុងការចូលខ្លួននៃមន្ត្រីជាន់ខ្ពស់ប្រាំមួយរូបនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត

១៥. សៀវភៅ Lemonde បង្ហាញដោយគ្មានមន្ទិលសង្ស័យថា ការខកខានរបស់អតីតសម្តេចព្រះនរោត្តម ស៊ីហនុ ហេង សំរិន ជា ស៊ីម ហោ ណាំហុង គាត ឈុន ស៊ីម កា និង អ៊ុក ប៊ុនឈឿន មិនឆ្លើយតបទៅនឹងកិច្ចប្រឹងប្រែងរបស់ចៅក្រម Lemonde ដើម្បីយកសក្ខីកម្មរបស់ពួកគេ រំលោភមាត្រាវិធាន៣៥(១)។ ជាដំបូងចៅក្រម Lemonde បញ្ជាក់ថាសាក្សីទាំងប្រាំពីររូប សំខាន់យ៉ាងខ្លាំងដល់កិច្ចស៊ើបសួរ[16]។ ជាបន្ទាប់ចៅក្រម Lemonde បរិយាយពីការគេចវេសជាបន្តបន្ទាប់របស់ចៅក្រម ប៊ុនឡេង ខណៈដែលចៅក្រម Lemonde ព្យាយាមពេលជាច្រើនខែដើម្បីលើកឡើងនូវបញ្ហានៃការចូលខ្លួនរបស់សាក្សី[17]។

---

ហើយខែកញ្ញា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេតមមាញឹកនឹងការពង្រាងដីកាដំណោះស្រាយនៅក្នុងករណី ០០២ ដែលមានកម្រាស់៨០០ ទំព័រ។ ការលាឈប់របស់ចៅក្រម Lemonde ចូលជាធរមានពីខែសីហា ឆ្នាំ២០១០ គឺពីរខែក្រោយការចេញដីកាដំណោះស្រាយនៅក្នុងករណី០០២។

[15] តាមពិតចៅក្រម Lemonde មានបទពិសោធន៍យ៉ាងច្បាស់អំពីការត្រួតត្រាជាប្រចាំងពីសំណាស់រាជរដ្ឋាភិបាលកម្ពុជាមកលើចៅក្រម យូ ប៊ុនឡេង ។ សូមមើលសៀវភៅ Lemonde នៅទំព័រ១៧២ (រៀបរាប់អំពីការស្ទាក់ស្ទើររបស់ចៅក្រម ប៊ុនឡេង ក្នុងការកោះហៅសាក្សីខាងក្នុងប្រាំមួយរូប (សូមមើលខាងក្រោម), 'Il réagit *comme souvent* dans *ce genre* de circonstances.') (បញ្ជាក់បន្ថែម)។

[16] សៀវភៅ Lemonde នៅទំព័រ១៧០-១៧១ (ពន្យល់ក្នុងន័យទូទៅអំពីភាពពាក់ព័ន្ធរបស់សាក្សីម្នាក់ក្នុងចំណោមសាក្សីប្រាំមួយនាក់ ហើយបានសន្និដ្ឋាន: 'Dès le début de l'année 2009, j'avais expliqué à You Bunleng qu'il nous fallait absolument interroger ces témoins.'). សូមមើលផងដែរកថាអក្សរក្នុងលេខយោងទី៣១ខាងក្រោម ។

[17] សៀវភៅ Lemonde នៅទំព័រ១៧២ ('Je savais, bien sûr, que l'idée n'était pas de nature à lui plaire'), 172-174 (generally).

កិច្ចប្រឹងប្រែទាំងនេះបានឈានទៅដល់ការស្តីបន្ទោសរបស់ចៅក្រម Lemonde ទៅលើចៅក្រម ប៊ុនឡោង ថាគាត់ត្រូវធ្វើការជ្រើសរើសជាយថាហេតុរវាងរដ្ឋាភិបាល និងតួនាទីរបស់គាត់ជាចៅក្រមស៊ើបអង្កេតម្នាក់[18]។ ជាចុងក្រោយចៅក្រម Lemonde កោះហៅសាក្សីដោយខ្លួនឯងដើម្បីប្រឈមនឹងការពន្យារពេល និងឧបសគ្គដែលបង្កឡើងដោយសាក្សី និងតំណាងរបស់ពួកគេតែប៉ុណ្ណោះ[19]។ ឧបសគ្គនេះបានឈានដល់ចំណុចកំពូលនៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានជូនដំណឹងដោយអ្នកតំណាងម្នាក់របស់សាក្សីម្នាក់ថា ចៅហ្វាយរបស់គាត់មិនអាចធ្វើតាមការកោះហៅរបស់ចៅក្រម Lemonde បានទេ ព្រោះបើតាមធ្វើការកោះហៅនេះ នឹងគ្រោះថ្នាក់ដល់អាជីពនយោបាយរបស់គាត់[20]។

១៦. នៅដំណាក់កាលនេះចៅក្រម Lemonde សម្រេចចាត់ចំណាត់ថ្នាក់ជាថ្មីនៃដីកាកោះហៅដើម្បីជូនដំណឹងដល់សាធារណជននៃការវិវត្តន៍ទាំងនេះ។ នៅក្នុងរូបភាពដែលហាក់ដូចជាចម្លងពីចៅក្រម Kasper-Ansermet ការចាត់ចំណាត់ថ្នាក់ជាថ្មីនៃដីកាកោះហៅរបស់ចៅក្រម Lemonde ត្រូវបានបដិសេធដោយផ្នែក CMS។ ទើបតែនៅពេលដែលចៅក្រម Lemonde ជួបមុខចៅក្រម ប៊ុនឡោង និងព្រមានចេញសេចក្តីប្រកាសព័ត៌មានដែលថា រដ្ឋបាលតុលាការទទួលការណែនាំពីរដ្ឋាភិបាលកម្ពុជា ទើបដីការបស់គាត់ត្រូវបានអនុវត្ត[21]។

១៧. ហេតុការណ៍ដែលកើតឡើងជាបន្តបន្ទាប់នេះ បង្កើតឲ្យមានការជឿជាក់ហួសពីវិមតិសង្ស័យថាទាំងផ្នែក CMS និងសាក្សីខ្លួនឯងជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ តាមរយៈការបដិសេធមិនធ្វើតាមដីការបស់ អវតក[22] ហើយថាចៅក្រម ប៊ុនឡោង តែងកងរំលោភវិធាន

---

[18] សៀវភៅ Lemonde នៅទំព័រ១៧៣ ('Je lui disais que j'étais bien conscient de la difficulté de sa position : la question que je le soulevais était à l'évidence plus délicate pour lui que pour moi. Nous échangions sans aucune animosité personnelle. Simplement, lorsque je lui expliquais qu'entre le gouvernement et le juge d'instruction il faudrait bien qu'il finisse par choisir, il était manifestement embarrassé.').

[19] សៀវភៅ Lemonde នៅទំព័រ១៧៤-១៧៧ ។

[20] សូមមើលកថាខណ្ឌ៩(ង)ខាងលើ ។

[21] សៀវភៅ Lemonde នៅទំព័រ១៧៧-១៧៨ ។

[22] វិធាន៣៥(១)(ខ)។

៣៥ តាមរយៈការជ្រៀតជ្រែកការចូលខ្លួនរបស់អ្នកដែលអាចក្លាយជាសាក្សី[23]។ វាក៏លេចឡើងនូវភវនីភាពដែរថា សាក្សីដដែលនោះទទួលរងសំពាធពីសំណាក់រដ្ឋាបាលកម្ពុជាមិនឱ្យផ្តល់សក្ខីកម្ម[24]។

១៨. អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការចូលខ្លួនរបស់សាក្សីទាំងនេះ គឺជាបញ្ហាដែលនៅតែត្រូវដោះស្រាយនៅក្នុងដំណើរការជំនុំជម្រះ អនុលោមតាមវិធាន៨៧[25]។ បើសិនជាពិត បញ្ហាថាតើបុគ្គលប្រាំមួយនាក់/ឬអ្នកផ្សេងទៀតបានជ្រៀតជ្រែកនៅក្នុងកិច្ចការតុលាការ គឺជាបញ្ហាមួយ ញែកចេញពីបញ្ហាថា តើពួកគេនឹងត្រូវបានស្តាប់សក្ខីកម្មនៅសវនាការដែរ ឬយ៉ាងណា[26]។ ការខកខានរបស់សាក្សីទាំងនេះមិនឆ្លើយតបទៅនឹងដីកាកោះហៅរបស់សហចៅក្រមស៊ើបអង្កេតនៅក្រោមកាលៈទេសៈដែលបានរៀបរាប់នៅក្នុងសៀវភៅ Lemonde តម្រូវឱ្យមានការស៊ើបសួរមួយអនុលោមតាមវិធាន៣៥(២)។

១៩. នៅដំណាក់កាលនេះការស៊ើបសួរបែបនេះមានសារៈប្រយោជន៍ច្រើនជាងប្រយោជន៍ខាងទ្រឹស្តី ក្រុមការពារក្តីជាច្រើនបន្តស្វែងរកឱ្យមានការចូលខ្លួនរបស់សាក្សីទាំងនេះនៅសវនាការ[27] តែ

---

[23] វិធាន៣៥(១)(ឃ)។

[24] វិធាន៣៥(១)(ឃ)។ ដូចដែលបានកត់សម្គាល់នៅក្នុងបណ្តឹងសារទុក្ខ ទង្វើបែបនេះបង្កើតបានជាការរំលោភដាច់ដោយឡែក និងការរំលោភតែឯកឯងនៃវិធាន៣៥។ ការខកខានមិនចូលខ្លួនគឺជាការជ្រៀកជ្រែតមួយនៅក្នុងរដ្ឋបាលតុលាការ។ សូមមើលបណ្តឹងសារទុក្ខភ្លាមនៅកថាខណ្ឌ៤៩-៥០។

[25] ឯកសារ E-116/7 "សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមដោយ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ"ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ERN 00794483-00794497នៅកថាខណ្ឌ៣២។

[26] បណ្តឹងសារទុក្ខនៅកថាខណ្ឌ៥១។

[27] ឯកសារ E-228, សំណើអនុលោមតាមវិធាន៨៧(៤)របស់លោក អៀង សារី សុំស្តាប់សក្ខីកម្មពី [redacted] និង [redacted] ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ERN 00846399-00846410 ។ ក្រុមមេធាវីការពារ នួន ជា បានព្យាយាមច្រើនលើកច្រើនសារសុំឱ្យមានការចូលខ្លួន [redacted] និង [redacted] នៅសវនាការ។ មេធាវីការពារបញ្ជាក់ពីជំហររបស់ខ្លួននៅក្នុងសារណានាពេលថ្មីបំផុត ដែលបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងភ្លាមៗបន្ទាប់កិច្ចប្រជុំរៀបចំសវនាការនាខែសីហា ឆ្នាំ២០១២ ហើយក្រោយមកបានផ្សព្វផ្សាយទៅភាគីទាំងអស់ ("សំណើសាក្សី នួន ជា")។ សារណានេះត្រូវភ្ជាប់មកជាមួយ។ សូមមើលឯកសារ E-236/5/1 "សំណើសុំកោះហៅសាក្សី TCW-223 ជាសាក្សីដែលពាក់ព័ន្ធនឹងអត្តចរិតរបស់ នួន ជា" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00889102-00889104 ។ បើទោះជា អៀង

កាលៈទេសៈទាំងឡាយដែលបណ្តាលឱ្យពួកគេមិនចូលខ្លួនក្នុងអំឡុងពេលស៊ើបសួរ មិនបានសម្រាល។ តាមពិត ករណី [redacted] និង [redacted] សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលស្គាល់យ៉ាងច្បាស់ថា បើទោះបីសាក្សីទាំងពីរនាក់នេះពាក់ព័ន្ធជាមួយការចោទប្រកាន់នៅក្នុងករណី០០២ ក៏គេមិនអាចយកសក្ខីកម្មរបស់ពួកគេបានដែរ[28]។ ដូចដែលមេធាវីការពារក្តីបានលើកអំណះអំណាងរួចហើយ[29] សៀវភៅ Lemonde រកឃើញថាការខកខានបែបនេះបង្កើតបានជាការជ្រៀតជ្រែកក្នុងរដ្ឋបាលតុលាការ។

២០. ទាក់ទងនឹង [redacted] និង [redacted] អង្គជំនុំជម្រះសាលាដំបូងបានបដិសេធរួចហើយនូវសំណើរបស់មេធាវីការពារក្តី សុំស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះ[30]។ ដូច្នេះវាមិនចាំបាច់

---

សារី បានស្លាប់ក្នុងពេលថ្មីៗ ដែលធ្វើឱ្យសំណើរបស់គាត់នឹងមិនមានតទៅទៀតនៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ ក៏មេធាវីការពារក្តីនៅតែគាំទ្រសំណើរបស់គាត់។ សូមមើលជើងទំព័រ២៨ខាងក្រោម។ ការពិតដែលក្រុមមេធាវីការពារក្តីសូមឱ្យមានវត្តមានសាក្សីទាំងនេះ គឺគាំទ្រថែមទៀតលើអំណះអំណាងរបស់មេធាវីការពារក្តីថា ពួកគេមានការពាក់ព័ន្ធសំខាន់ណាស់សម្រាប់សំណុំរឿង ០០២។ ពិសេសជាងនេះទៀតនោះ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពី [redacted] និង [redacted] បន្តបង្ហាញភាពតានតឹងរវាង សារសំខាន់របស់សាក្សីទាំងនេះ និង ការលំបាកក្នុងការទទួលបានសក្ខីកម្ម។ សូមមើលជើងទំព័រ ២៨ និង ៣៣ ខាងក្រោម។

[28] ឯកសារ E-228/1 "ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើអនុលោមតាមវិធាន៨៧(៤)របស់លោក អៀង សារី សុំស្តាប់សក្ខីកម្មពី [redacted] ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ ERN 00849279-00849283, នៅកថាខណ្ឌ៤។ បើទោះបីសហព្រះរាជអាជ្ញាអន្តរជាតិមិនបានកំណត់ឱ្យបានច្បាស់លាស់ថាការខកខានមិនចូលខ្លួន ជាការជ្រៀកជ្រែតនៅក្នុងរដ្ឋបាលតុលាការ ។ សូមមើលឯកសារ E-228/2 "ញត្តិគាំទ្រសំណើរបស់ អៀង សារី សុំស្តាប់សក្ខីកម្មពី [redacted] និង [redacted] ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ ERN 00853849-00853853 នៅកថាខណ្ឌ៥-៦ ។ ឯកសារ E-228/3 "ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងញត្តិរបស់ នួន ជា "គាំទ្រសំណើរបស់ អៀង សារី សុំស្តាប់សក្ខីកម្មពី [redacted]" ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១២ ERN 00857214-00857219 នៅកថាខណ្ឌ១២ ។ ឯកសារ E-228/4 "សារណាឆ្លើយតទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះញត្តិរបស់ នួន ជា "គាំទ្រសំណើរបស់ អៀង សារី សុំស្តាប់សក្ខីកម្មពី [redacted]" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ERN 00864439-00864444 នៅកថាខណ្ឌ៩-១០។

[29] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤៧-៥០ ។

[30] ឯកសារ **E-236/1**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង កម្មវត្ថុ៖សាក្សីដែលផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន, ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១២, ERN 00850147-00850148, កថាខណ្ឌទី៦។

ទទួលយកសេចក្តីសម្រេចមួយចំនួនទៀតនៅពេលអនាគតអ្វីទៀតឡើយពាក់ព័ន្ធនឹងការចូលខ្លួនរបស់ពួកគេនៅតុលាការ។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនបែបនេះដោយមិនបានផ្តល់សំអាងហេតុត្រឹមត្រូវ ហើយខកខានសូម្បីតែដោះស្រាយទឡ្ហីករណ៍ដែលបានដាក់ជូនដោយមេធាវីការពារក្តី ដែលថាសាក្សីទាំងពីររូបនេះមានភស្តុតាងសំខាន់បំផុតដែលមិនអាចរកបានពីប្រភពដទៃទៀត[31]។ ដូចជា

---

[31] សំណើរបស់ នួន ជា សុំស្តាប់សក្ខីកម្មសាក្សី, កថាខណ្ឌ៣១ ដល់៣៧។ ដូចដែលមេធាវីការពារក្តីបានពន្យល់នៅក្នុងសំណើនោះ ពួកគេមិនមែនជាសាក្សីសាមញ្ញឡើយ។ [redacted] និង [redacted] ជាមន្ត្រីយោធាថ្នាក់ខ្ពស់ដែលបានដឹងព្រឹត្តិការណ៍ពាក់ព័ន្ធមុនគេ ក្នុងដីកាដំណោះស្រាយ។ ជាពិសេស ក្នុងជួរកងទ័ពពិសេសរបស់ខ្មែរក្រហម [redacted] គឺជាមេបញ្ជាការរងនៃកងពលធំមួយក្នុងចំណោមកងពលធំពីររបស់ទាហានខ្មែរក្រហមដែលរួមមានកងទ័ពភូមិភាគបូព៌ាផងដែរ ហើយ [redacted] បានមកដល់វិមាន ឯករាជ្យក្នុងឋានៈដដែលនេះកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៩ព្រឹក។ និយាយឱ្យស្រួលស្តាប់ជាងនេះបន្តិចទៅ [redacted] គឺស្ថិតក្នុងក្រុមតូចមួយនៃមន្ត្រីជាន់ខ្ពស់បំផុតដែលបានរំដោះទីក្រុងភ្នំពេញយ៉ាងសកម្ម។ គាត់គឺជាមន្ត្រីដែលមានឋានៈខ្ពស់បំផុតដែលនៅរស់រានមានជីវិតរហូតសព្វថ្ងៃនេះ។ សារៈសំខាន់នៃទស្សនវិស័យតែមួយគត់គ្មានពីរចំពោះការជំនុំជម្រះដែលចេះតែបន្តអាចត្រូវបានគេយល់យ៉ាងច្បាស់ដោយសារតែកត្តាពីរយ៉ាងប៉ុណ្ណោះ (i) ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលចាប់ផ្តើមកាលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ គឺជាចំនុចសំខាន់នៃសំណុំរឿង០០២/០១ (ii) មានភស្តុតាងគ្រប់គ្រាន់ដែលថាកងទ័ពភូមិភាគបូព៌ាដែលបានវាយកាន់កាប់ទីក្រុងភ្នំពេញ បានបំពេញការងារដោយឯករាជ្យ និងក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំភូមិភាគរបស់ពួកគេដែលជាលោក [redacted] មិនមែនមជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តឡើយ។ សូមមើល*ឧទាហរណ៍* ឯកសារ**E-3/20** “នៅពេលដែលសង្គ្រាមរលត់ទៅ”, ឯកសារ ERN 00237694-00238316,ទំព័រ១៧៣ ដល់១៧៤។ (ប៉ុន្តែ តាមពិតទៅកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ ស្ថិតក្នុងជួរកងទ័ព៦ប្រភេទដាច់ដោយឡែកពីគ្នាដូចជាកងទ័ពរបស់ភូមិភាគឧត្តរ, ភូមិភាគ ភូមិភាគបូព៌ា, ភូមិភាគនិរតី, ភូមិភាគពាយព្យ និងភូមិភាគពិសេស។ ដោយសារតែភាពចាំបាច់ និងការបង្គាប់បញ្ជាខាងបដិវត្តន៍ឱ្យមានប្រព័ន្ធសហការណ៍ មេដឹកនាំភូមិភាគដែលជាលេខាភូមិភាគរបស់បក្សដែលត្រូវបានតែងតាំងកាលពីមុនដោយថ្នាក់ដឹកនាំបក្សគឺជាអ្នកទទួលខុសត្រូវខាងយោធា, ទទួលខុសត្រូវលើបក្ស និងជនស៊ីវិលដែលរស់នៅក្នុងតំបន់ដែលពួកគេកាន់កាប់។ មេដឹកនាំភូមិភាគនីមួយៗត្រូវបានគេរំពឹងថានឹងបំពេញកិច្ចការពាក់កណ្តាលដោយខ្លួនឯងមិនចាំបាច់មានបញ្ជាពីថ្នាក់លើ), ឯកសារ E-3/9, “ប៉ុល ពត, History of a nightmare ”, ERN ERN 00396177-00396757, ទំព័រ២៧២ (ដើម្បីជៀងវាងការភ័ន្តច្រឡំ កងទ័ពមកពីភូមិភាគ៤ផ្សេងគ្នាដែលទទួលខុសត្រូវវាយកាន់កាប់ទីក្រុងភ្នំពេញ បានចេញបញ្ជាផ្សេងពីគ្នា), ទំព័រ ២៧៤។ ពួកភាគនិរតីត្រូវបានសម្រិតសម្រាំងខ្លាំងជាងភូមិភាគផ្សេងទៀតដែរដើម្បីប្រព្រឹត្តទៅលើទាហានសាធារណៈរដ្ឋ។ មន្ត្រីជាន់ខ្ពស់មួយចំនួនត្រូវបានសម្លាប់ ហើយមន្ត្រីថ្នាក់ កណ្តាល និង NCOs ត្រូវបានទុកជីវិត។ ឯកសារ **E-3/1593**, របបប៉ុលពត : ពូជសាសន៍, អំណាច និងអំពើប្រល័យពូជសាសន៍ ក្នុង

ករណី [redacted] មានហេតុផលគួរឱ្យជឿជាក់ថា គាត់មានភស្តុតាងដោះបន្ទុកដោយផ្ទាល់[32]។ ដោយសារតែសារៈសំខាន់យ៉ាងច្បាស់ក្រឡែតនៃសាក្សីទាំងពីរខាងលើ និងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់មូលហេតុឱ្យបានគ្រប់គ្រាន់លើសេចក្តីសម្រេចរបស់ខ្លួនមិនព្រមស្តាប់សក្ខីកម្មរបស់ពួកគេ និងមិនព្រមទទួលយកសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងការលំបាកក្នុងការទទួលបានការចូលខ្លួនរបស់សាក្សី

---

ប្រទេសកម្ពុជាក្រោមសម័យខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់៧៩, ឯកសារ ERN 00678476-00678740, ទំព័រ៣៨។ (អ្នកឧត្តរ បានត្រូវគេស្គាល់ភ្លាមដោយសារតែការប្រើវិធីសាស្ត្រកាចសាហាវរបស់ពួកគេជាងកម្លាំងនៅនិរតី និងនៅក្នុងភូមិភាគពិសេស),ទំព័រ៤៣។ ("អ្នកបូព៌ាប្រើវិធីសាស្ត្រត្រជាក់។ ពួកគេបានចែកថ្នាំពេទ្យ និងអង្ករជូនប្រជាជនតាមផ្លូវ"។ មិនដូចជាពួកនិរតីឡើយ ពួកគេមិនបាន បើកការប្រយុទ្ធគ្នាទេ... កម្លាំងនៅភូមិភាគបូព៌ាជាទូទៅមានអត្តចរិតល្អជាងគេ) ,ទំព័រ៤៧ (...គាត់យល់ឃើញ ថាពួកអាវខ្មៅនៅភូមិភាគឧត្តរ ពិតជាកាចសាហាវចំពោះជនភៀសខ្លួនខ្លាំងណាស់ ។ នៅពេលជាមួយគ្នានោះ ពួកខ្មែរក្រហមទាំងនេះ បានរិះគន់យ៉ាងខ្លាំងដល់ពួកខ្មែរក្រហមដ៏ទៃទៀតដែលឈោជើងនៅត្រើយម្ខាងទៀតនៃស្ទឹងក្នុងភូមិភាគបូព៌ា...[ទាហាននៅបូព៌ា] ជួយយកអាសារប្រជាជនខ្លាំងណាស់... ពោលគឺទាហានចិត្តល្អ) ។ គ្មានបុគ្គលណាទៀតដែលបានដឹងអំពីទំនាក់ទំនងរវាងមជ្ឈិមបក្ស និងមេដឹកនាំភូមិភាគប្រហាក់ប្រហែលនឹង [redacted] ត្រូវបានពិចារណាយកជាសាក្សីសក្តានុពលក្នុងសំណុំរឿង០០២ឡើយ (ករណីលើកលែងដែលអាចកើតឡើងតែមួយគត់គឺសាក្សី [redacted], ដែលជាជនសង្ស័យម្នាក់ក្នុងសំណុំរឿង០០៣ ដែលមិនត្រឹមតែទទួលបានការការពារពីរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានសិទ្ធិនៅស្ងៀមផងដែរ)។ បុគ្គលទាំងពីររូបនេះគឺជាអ្នកដែលបានចូលរួមកិច្ចប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ដែលគេនិយាយថាពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យទៅលើមន្ត្រីសាធារណៈរដ្ឋ។ ប៉ុន្តែបុគ្គលទាំងពីររូបនេះបានពិពណ៌នាកិច្ចប្រជុំនេះទៅកាន់លោក Ben Kiernan ថា៖ ផ្ទុយទៅវិញ [redacted] បានអះអាងថា នួន ជា បានបញ្ជាឱ្យ "កម្ទេច" មន្ត្រីសាធារណៈរដ្ឋ ប៉ុន្តែ [redacted] បានច្រានចោលការចងចាំបែបនេះ ហើយគាត់បានលើកឡើងថា នួន ជា បានប្រើឃ្លាខុសពីនេះ គឺគ្រាន់តែឱ្យគេ "វាយឱ្យខ្ចាត់ខ្ចាយ" តែប៉ុណ្ណោះ។ ដូច្នេះ សក្ខីកម្មរបស់ [redacted] ពិតជាភស្តុតាងដោះបន្ទុកដោយផ្ទាល់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំង នួន ជា ហើយបានផ្តល់ភស្តុតាងគាំទ្រទៅដល់ការអះអាងជាយូរមកហើយរបស់មេធាវីការពារក្តីដែលថាឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងគឺទទួលបញ្ជាពីមន្ត្រីថ្នាក់ក្រោម ឬគ្មានបញ្ជាអ្វីទាំងអស់។ ដូចដែលអង្គជំនុំជម្រះបានទទួលស្គាល់ដោយឥតសង្ស័យថាការចងចាំរបស់ [redacted] អំពីកិច្ចប្រជុំនេះ គឺមិនត្រឹមតែពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនេះដោយផ្ទាល់ទេ ប៉ុន្តែវាក៏អាចបង្កើតជាសំនួរមួយផងដែរៈតើគាត់ស្គាល់នរណាទៀតក្នុងកិច្ចប្រជុំនោះ? ដោយសារតែគាត់បដិសេធមិនព្រមសហការជាមួយតុលាការ ដូច្នេះ សំណួរនេះ គ្មានចម្លើយឡើយ។

[32] សំណើសុំកោះហៅសាក្សីរបស់ នួន ជា, កថាខណ្ឌ៣៣ ដល់៣៤។

ដែលស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះ ([redacted]) នោះឥទ្ធិពលនៃការជ្រៀតជ្រែកដែលចេះតែបន្ត និងដែលកំពុងរងការរិះគន់ គឺមិនអាចប្រកែកបានឡើយ[33]។

**iii. សេរីភាពនៃការធ្វើសកម្មភាពរបស់ចៅក្រមអន្តរជាតិកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់**

២១. អ្វីដែលគួរឲ្យចាប់អារម្មណ៍បំផុតអំពីសៀវភៅ Lemonde គឺគ្រោះថ្នាក់ដែលសៀវភៅនេះបានបង្ហាញថា មិនត្រឹមតែចៅក្រមជាតិប៉ុណ្ណោះទេ សូម្បីតែចៅក្រមអន្តរជាតិក៏ទទួលរងសម្ពាធដែលផ្ទុយទៅនឹងកាតព្វកិច្ចរបស់ពួកគេដែលត្រូវបំពេញកិច្ចការដោយឯករាជ្យនៅ អវតកដែរ។ ចៅក្រម Lemonde បានលើកឧទាហរណ៍មួយមកនិយាយដែលក្នុងនោះ គាត់សម្រេចមិនលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធយ៉ាងខ្លាំង ប៉ុន្តែមានលក្ខណៈរសើបខាងនយោបាយតាមសំណើរបស់ចៅក្រម យូ ប៊ុនឡេង[34]។ នេះជាឧទាហរណ៍ដ៏រឹងមាំដែលបញ្ជាក់ថា ចៅក្រមអន្តរជាតិនៅ អវតក ធ្វើតាមការទាមទាររបស់រដ្ឋាភិបាលកម្ពុជា ដើម្បីបិទបាំងឥទ្ធិពលរបស់ខ្លួនទៅលើតុលាការនេះ។ ករណីនេះត្រូវបានពិព័ណ៌នាដោយសេរីដោយចៅក្រម Lemonde ខ្លួនឯង។

២២. សៀវភៅ Lemonde ក៏បានបង្ហាញផងដែរថា ចៅក្រមអន្តរជាតិបានជួបជុំគ្នាដើម្បីពិភាក្សាអំពី "បញ្ហាក្រមសីលធម៌មូលដ្ឋាន" ដែលបង្កឡើងដោយការថ្លែងជាសាធារណៈរបស់លោក ហោ ណាំហុង ដែលបានរិះគន់យ៉ាងខ្លាំងទៅលើដីកាកោះហៅគាត់មកផ្តល់សក្ខីកម្មនៅតុលាការ ។ ចៅក្រម Lemonde ខ្លួនគាត់ផ្ទាល់បារម្ភថា ប្រសិនបើគ្មានប្រតិកម្មតបណាមួយទេ នោះសេរីភាពនៃធ្វើកិច្ចការរបស់ចៅក្រមអន្តរជាតិ អាចនឹងត្រូវបានបំផ្លាញដោយផ្ទាល់នៅ

---

[33] ដើម្បីឲ្យច្បាស់ មេធាវីការពារក្តីមេធាវីការពារក្តីសង្កត់ធ្ងន់ថាក្នុងញត្តិនេះមិនមែនជាការជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គ ជំនុំជម្រះសាលាដំបូងមិនកោះហៅសាក្សីឡើយ។ មេធាវីការពារក្តីគ្រាន់តែចង់ជម្រាបអង្គជំនុំជម្រះតុលាការកំពូលឲ្យដឹងអំពីអង្គ ហេតុជាច្រើនក្នុងគោលបំណងដើម្បីបង្ហាញថាខ្លួននៅតែបន្តចង់ឲ្យសាក្សីទាំងនោះមកបង្ហាញខ្លួននៅតុលាការ និងដើម្បីបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងនៅតែស្ទាក់ស្ទើរក្នុងការកោះហៅសាក្សីទាំងនោះឲ្យមកផ្តល់សក្ខីកម្ម។ បើពិនិត្យមើលទៅលើកាលៈទេសៈរួមមេធាវីការពារក្តីយល់ឃើញថាវាទំនងជាអាចទៅរួចដែលថាគោលជំហររបស់សាក្សីទាំងនោះក្នុងជួររដ្ឋាភិបាល និងការបដិសេធ របស់ពួកគេមិនព្រមធ្វើតាមដីកាកោះដែលចេញដោយចៅក្រម Lemond នៅតែបន្ត(យ៉ាងហោចណាស់) ធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង។

[34] សូមមើលកថាខណ្ឌ៤(ង), ដូចខាងលើ។

ពេលអនាគត ។ ដូច្នេះ ចៅក្រម Cartwright តាំងនាមឱ្យចៅក្រមអន្តរជាតិទាំងអស់បានសរសេរលិខិតមួយទៅកាន់លោកស្រី Patricia O'Brien ប្រធានទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ ។ ជាការឆ្លើយតប លោកស្រី Patricia O'Brien បានធានាដល់ចៅក្រមអន្តរជាតិថាដោយសារតែនៅពេលថ្មីៗនេះ លោក សុខ អាន បានបញ្ជាក់ពីការគាំទ្ររបស់រដ្ឋាភិបាលកម្ពុជាចំពោះឯករាជ្យភាពរបស់ អវតក ដូច្នេះគេគ្មានមូលហេតុដែលត្រូវព្រួយបារម្ភឡើយ ។ ដោយអត្ថាធិប្បាយលើករណីនេះ ចៅក្រម Lemonde អាចគ្រាន់តែធ្វើការសង្កេតថា "យើងត្រូវបានគេបង្ខំឱ្យយល់ស្របជាមួយនឹង "ការគាំទ្រនេះ"។

២៣. រឿងរ៉ាវរបស់ចៅក្រម Lemonde ស្តាប់ទៅយើងដូចជាធ្លាប់ឮដែរ។ តាមពិតមេធាវីការពារក្តីបានតវ៉ាជាច្រើនលើកច្រើនសារួចមកហើយ អំពីការថ្លែងស្រដៀងគ្នានេះពីសំណាក់សមាជិកជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលជាមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា[35]។ ជាញឹកញាប់ អង្គជំនុំជម្រះ និងសូម្បីតែចៅក្រម Lemonde បានច្រានចោលក្តីបារម្ភរបស់យើងយ៉ាងហោចណាស់ក៏មួយលើកដែរ ដោយចាត់ទុកក្តីបារម្ភនេះថា មិនច្បាស់លាស់ លើកឡើងច្រំដែលៗដើម្បីគាំទ្រ អវតក ថា ឯករាជ្យពីរាជរដ្ឋាភិបាលកម្ពុជា[36]។ ពិតណាស់ ការថ្លែងដែលធ្វើឱ្យចៅក្រមមានបញ្ហាខ្លាំងបំផុត គឺសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលក្នុងនោះចៅក្រម Lemonde *ខ្លួនគាត់ផ្ទាល់* យល់ឃើញដោយគ្មានសំអាងហេតុត្រឹមត្រូវថា "ការចោទប្រកាន់

---

[35] ឯកសារ **D-254/2**, "សំណើសុំធ្វើការស៊ើបអង្កេត", ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩, ERN 00410058-00410960, កថាខណ្ឌទី៤, ឯកសារ No. **E-176**, សំណើតាមវិធាន៣៥ សុំចំណាត់ការបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន, ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២, ERN 00782947-00782959, ឯកសារ **E-219**, "សំណើតាមវិធាន៣៥ សុំចំណាត់ការបន្ទាន់ប្រឆាំងរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង", ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២, ERN 00834491-00834500, ឯកសារ **E-219/1**, "សារណាបន្ថែមចំពោះសំណើតាមវិធាន៣៥ សុំចំណាត់ការបន្ទាន់ប្រឆាំងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង", ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២, ERN 00838725-00838727 ។

[36] ឯកសារ. **E-219/3** , "សេចក្តីលើសំណើតាមវិធាន៣៥សុំចំណាត់ការបន្ទាន់ប្រឆាំងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង" (E219), ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២, ERN 00864703-00864711, កថាខណ្ឌ១៤។

ក្នុងសំណើសុំកោះហៅសាក្សីមិនសមទទួលបានការអនុវត្តន៍នៃបទបញ្ញត្តិក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុងឡើយ”[37]។

២៤. ដោយសារតែការខកខានជាបន្តបន្ទាប់មិនបានចាត់វិធានការរបស់អង្គជំនុំជម្រះ ការថ្លែងរបស់ ហោ ណាំហុង និងអ្នកដទៃទៀតដែលចង់ធ្វើដូចគាត់ នៅតែបន្តកើតឡើងក្នុងរយៈពេល ៧ឆ្នាំក្រោយមកទៀត “ដោយគ្មានប្រត្តិកម្មតបអ្វីទាំងអស់”។ វាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលចៅក្រម Lemonde បានលើកឡើងដែលថា “សេរីភាពនៃការធ្វើសកម្មភាពរបស់ចៅក្រមអន្តរជាតិ ត្រូវបានបំផ្លាញដោយផ្ទាល់”។

## iv. ព័ត៌មានសម្ងាត់បែកធ្លាយដល់រដ្ឋាភិបាលកម្ពុជា

២៥. ក្នុងសម្រង់ដទៃទៀតចៅក្រម Lemonde បានពិពណ៌នាអំពីពិធីជប់លៀងមួយក្នុងខែ កក្កដា ឆ្នាំ ២០០៩ នៅស្ថានទូតបារាំងប្រចាំនៅកម្ពុជា ដែលលោក គាត ឈន់ បានចូលរួមជាតំណាងរាជរដ្ឋាភិបាលកម្ពុជា។ លោក គាត ឈន់ បានថ្លែងសុន្ទរកថា។ ចៅក្រម Lemonde រៀបរាប់ពីទិដ្ឋភាពដូចខាងក្រោម៖

> ភ្ញៀវទាំងអស់ឈរជារង្វង់មូល ហើយជាការគាប់ជួន ខ្ញុំបានឈរទល់មុខ [គាត ឈន់]។ គាត់ស្គាល់ខ្ញុំច្បាស់ណាស់ ហើយគាត់បានទទួលព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងរឿងរ៉ាវដែលកំពុងកើតឡើង ហើយខ្ញុំដឹងថា គាត់ដឹង។ នៅពេលដែលគាត់ ថ្លែងសុន្ទរកថាចប់ គាត់សម្លឹងចំមកខ្ញុំ ហើយលើកកែវ ហើយស្រែកថា “សាធារណៈរដ្ឋបារាំងដ៏រុងរឿង!”។ ភ្លាមៗនោះ ខ្ញុំមានអារម្មណ៍ថាដូចជាតួកុន Clint Easwood កំពុងប្រយុទ្ធគ្នាជាមួយ Lee Van Cleef... ខ្វះតែភ្លេង Enrico Morricone តែប៉ុណ្ណោះ[38] ។

---

[37] ឯកសារ **D-314/3**, “ដីកាបង្គាប់ឆ្លើយតបទៅនឹងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គជំនុំជម្រះលើសំណើរបស់ នួន ជា និង អៀង សារី សុំកោះហៅសាក្សី”, ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០, ERN 00532792-00532794, កថាខណ្ឌទី៥ ដល់៦។

[38] សៀវភៅ Lemonde, ទំព័រ១៧៥។

២៦. ឧបុត្តិហេតុនេះបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាមានព័ត៌មានពាក់ព័ន្ធនឹងការពិភាក្សាសម្ងាត់រវាងសហចៅក្រមស៊ើបអង្កេត។ អកប្បកិរិយាធម្មតារបស់ចៅក្រម Lemonde ក្នុងបរិបទនោះបង្ហាញឱ្យឃើញច្បាស់ថា វាមិនបានកើតឡើងដោយឯងៗនោះទេ។ សំខាន់ជាងនេះទៅទៀត វាក៏បង្ហាញភស្តុតាងបន្ថែមទៀតដែរថា សូម្បីតែចៅក្រមអន្តរជាតិក៏មានអារម្មណ៍ហាក់បីដូចជាត្រូវទទួលការគំរាមកំហែងពីរដ្ឋាភិបាលកម្ពុជាផងដែរ។ ករណីនេះមិនធ្លាប់លាតត្រដាងឱ្យភាគីបានដឹងឡើយ។

## V. សេចក្តីសន្និដ្ឋាន

២៧. មេរៀនគ្រឹះក្នុងសៀវភៅរបស់លោក Lemonde គឺថាបើនិយាយពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលកម្ពុជា ភាពខុសប្លែកគ្នារវាងសំណុំរឿង ០០៣ និង ០០៤ ហើយ ០០១ និង ០០២ គឺមិនដែលសមហេតុផលឡើយ។ បទពិសោធន៍របស់ចៅក្រម Lemonde ជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ គឺជាការគាំទ្រយ៉ាងខ្លាំងចំពោះកំណត់ហេតុរបស់ចៅក្រម Kasper ប៉ុន្តែនេះគ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ ពាក់ព័ន្ធនឹងវិធីសាស្ត្រដែលរដ្ឋាភិបាលកម្ពុជាធ្វើឱ្យការជ្រៀតជ្រែករបស់ខ្លួនធ្វើដំណើរទៅមុខកាត់ភាពខុសប្លែកគ្នានេះបានយ៉ាងរលូន។ ដូចអ្វីដែលបទពិសោធន៍របស់ចៅក្រម Lemonde បានបង្ហាញ ឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជាទៅលើកិច្ចដំណើរការនីតិវិធីនៅ អវតក គឺផ្ទុយនឹងរដ្ឋធម្មនុញ្ញ។ ការជ្រៀតជ្រែករបស់រដ្ឋាភិបាលបានភ្ជាប់ទៅនឹងភារកិច្ចរបស់តុលាការ ហើយតួនាទីរបស់តុលាការត្រូវបានភ្ជាប់ជាមួយនឹងបរិបទនយោបាយច្រើនជាង។ ពិតណាស់ចៅក្រម Lemonde បានសរសើរអំពីចរិកលក្ខណៈបុគ្គលរបស់ចៅក្រម ប៊ុនឡេង ទោះបីជានៅពេលដែលគាត់បានរិះគន់ខ្លាំងៗចំពោះការិយាល័យរបស់គាត់ដែលខកខានមិនបានបំពេញតាមក្រមសីលធម៌ក៏ដោយ[39]។ ការិយាល័យនោះមិនអាចស្ថិតនៅក្រោមការបង្គាប់បញ្ជាពីអ្នកណាឡើយ ប៉ុន្តែត្រូវរងការបង្គាប់បញ្ជាពីសំណាក់រដ្ឋាភិបាលកម្ពុជា។ ដោយសារតែមូលហេតុនេះហើយទើបធ្វើឱ្យចៅក្រមអន្តរជាតិត្រូវរងនឹងសម្ពាធដូចគ្នាទៅនឹងចៅក្រមជាតិដែរ។ ដូច្នេះការរំលោភយ៉ាងច្បាស់ក្រឡែតលើវិធាន ៣៥ នៃ

---

[39] សៀវភៅ Lemonde, ទំព័រ៣១។

វិធានផ្ទៃក្នុងដែលបានរៀបរាប់យ៉ាងច្បាស់ក្នុងសៀវភៅរបស់លោក Lemonde គឺគ្រាន់តែជាសញ្ញាដ៏តូចមួយនៃបញ្ហាដ៏ធំតែប៉ុណ្ណោះ។

## ឃ. អង្គជំនុំជម្រះតុលាការកំពូលមិនគួរទទួលយកការរកឃើញណាមួយដែលធ្វើឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេតឡើយ។

២៨. សេចក្តីសម្រេចដែលមានការជំទាស់នេះលើកឡើងថា ការចោទប្រកាន់ក្នុងសំណើដើមកាលពីមុនត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[40]។ សេចក្តីសម្រេច ដែលធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូលភាគច្រើនយល់ស្របទៅនឹងការសម្រេចកាលពីលើកមុន នៅដំណាក់កាលស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ[41]។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ទោះបីខ្លួនមានអំណាចចាត់វិធានការណ៍តាមវិធាន ៣៥ លើបញ្ហាដែលបានកើតឡើងក្នុងដំណាក់កាលស៊ើបអង្កេតក៏ដោយ ប៉ុន្តែក្នុងករណីនេះ វាមិនសមស្របឡើយក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិនេះ ព្រោះបញ្ហាដែលកំពុងប្រឈមទាំងនេះគឺជាកម្មវត្ថុនៃការជំទាស់តវ៉ាតាមផ្លូវតុលាការដ៏ទូលំទូលាយរួចទៅហើយ[42]។

២៩. សៀវភៅ Lemonde បានផ្តល់ហេតុផលល្អដើម្បីអនុវត្តអំណាចឆន្ទានុសិទ្ធិនោះនៅពេលនេះ។ សៀវភៅនោះបានបង្ហាញថា ទោះបីជាមានការប្តឹងជំទាស់ពាក់ព័ន្ធនឹងសញ្ញាមួយចំនួននៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជាក៏ដោយ ប៉ុន្តែភាគីមិនបានដឹងព័ត៌មានពាក់ព័ន្ធទាំងអស់ឡើយ។ ជាងនេះទៅទៀត គឺចៅក្រម Lemonde ខ្លួនគាត់ផ្ទាល់ដែលបានលាក់ព័ត៌មាននេះដោយចេតនាមិនឲ្យមេធាវីការពារក្តីដឹង។ សម្រាប់មូលហេតុដែលបានគូសបញ្ជាក់ពីខាងលើ

---

[40] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌទី៨។

[41] ឯកសារ **E-116/7**, "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពត្រឹមត្រូវនៃការស៊ើបអង្កេត", ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២, ERN 00794483-00794497 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើភាពត្រឹមត្រូវនៃការស៊ើបអង្កេត"), ឯកសារ **E-116**, សេចក្តីសម្រេចលើសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេត(E51/3, E82, E88 and E92) , ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១, ERN 00729330-00729339, កថាខណ្ឌ២១។

[42] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើភាពត្រឹមត្រូវនៃការស៊ើបអង្កេត, កថាខណ្ឌទី៣១ដល់៣២។

ព័ត៌មាននោះ គឺពាក់ព័ន្ធទៅនឹងបញ្ហាថាតើបទដ្ឋាននៃវិធាន៣៥ ត្រូវបានបំពេញដែរ ឬអត់ ដូច្នេះវាពាក់ព័ន្ធទៅនឹងសេចក្តីសម្រេច ដែលបានធ្វើឡើងកាលពីមុនដំបូងដោយសហចៅក្រមស៊ើបអង្កេត និងការសម្រេចលើបណ្តឹងសារទុក្ខដោយអង្គបុរេជំនុំជម្រះ ហើយបន្ទាប់មកទៀតសេចក្តីសម្រេចទាំងពីរនេះ ត្រូវបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល។

៣០. សៀវភៅ Lemonde ក៏បានលើកឡើងផងដែរថាចៅក្រម Lemonde ព្រួយបារម្ភយ៉ាងខ្លាំងអំពីឯករាជ្យភាពរបស់ចៅក្រមកម្ពុជានៅ អវតក នៅពេលមួយដែលរូបគាត់ និងចៅក្រម យូ ប៊ុនឡេង បានបដិសេធចោលសំណើសុំធ្វើការស៊ើបអង្កេតជាច្រើនថាជាសំណើគ្មានមូលហេតុសមស្រប។ ជាមួយគ្នានេះ អង្គជំនុំជម្រះសាលាដំបូងក៏មានក្តីបារម្ភស្រដៀងគ្នានេះដែរ ហើយបានពិភាក្សាអំពីការស្វែងរកការជួយជ្រោមជ្រែងពីអង្គការសហប្រជាជាតិ។ ប៉ុន្តែមិនមានសេចក្តីសម្រេចណាមួយចេញពីអង្គជំនុំជម្រះ ដែលឆ្លុះបញ្ចាំងពីទស្សនៈពិតប្រាកដរបស់ចៅក្រមទាំងនេះអំពីឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជាទៅលើដំណើរការនីតិវិធីនៅ អវតក ឡើយ។ ដោយមិនបានចាត់វិធានការតាមក្តីបារម្ភរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបែរជាសម្រេចដាក់ទណ្ឌកម្មមេធាវីការពារក្តីដោយសារតែការលើកឡើងពីបញ្ហានេះច្រើនដងពេក[43]។

៣១. មេធាវីការពារក្តីទទួលស្គាល់ថា គំនិតឯកជនរបស់ចៅក្រមម្នាក់មិនពាក់ព័ន្ធទៅនឹងសុពលភាពនៃសេចក្តីសម្រេចរបស់តុលាការឡើយ។ ប៉ុន្តែ យោបល់ទាំងនោះ ពិតជាមានសារៈសំខាន់ចំពោះអង្គជំនុំជម្រះនេះ ដើម្បីធ្វើការពិចារណាថាតើ សេចក្តីសម្រេចទាំងនោះសមនឹងទទួលបានការគោរពដែរឬយ៉ាងណា។ ក្នុងកាលៈទេសៈបែបនេះ វាជាការទទួលខុសត្រូវរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការអនុវត្តអំណាចឥស្សរៈចិត្តរបស់ខ្លួនដើម្បីការពារសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធី។

## ង.អង្គជំនុំជម្រះតុលាការកំពូលមានកាតព្វកិច្ច និងអន្តានុសិទ្ធិឯករាជ្យក្នុងការចាត់វិធានការ

---

[43] ឯកសារ **E-214/3.2**, ការប្តឹងទៅកាន់គណៈមេធាវីទីក្រុង Amsterdam និង New York, , ERN 00821219-00821229, ទំព័រទី១០។

៣២. ដោយសារតែខ្លឹមសារនៃវិធាន៣៥(២) បានបញ្ជាក់យ៉ាងច្បាស់ថាអង្គជំនុំជម្រះនៅ អវតក នៅតែមានអំណាចឆន្ទានុសិទ្ធិ ដើម្បីបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ទាប់ពីរកឃើញមូលហេតុ ដែលគួរឱ្យជឿជាក់បានថា ពិតជាមានបុគ្គលជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់ តុលាការ។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបានកំណត់ឱ្យបង្រួមលក្ខខណ្ឌក្នុង វិធាន១០៨(៧) ឬការរកឃើញយ៉ាងច្បាស់របស់អង្គជំនុំជម្រះលើបណ្ដឹងសារទុក្ខ ឬក៏មិន តម្រូវឱ្យធ្វើការញែកឱ្យដាច់ស្រឡះដោយប្រុងប្រយ័ត្នថា តើអង្គហេតុណាមួយដែលពីមុនមក ត្រូវបានប្ដឹងជំទាស់ឡើយ។ សៀវភៅ Lemonde និងកំណត់ហេតុរបស់ចៅក្រម Kasper-Ansermet បានបង្ហាញពីភស្តុតាងថ្មីដ៏គួរឱ្យទុកចិត្តជាទីបំផុត ដែលធ្វើឱ្យមានការផ្លាស់ប្ដូរ យ៉ាងខ្លាំងចំពោះការពិពណ៌នាដែលធ្លាប់មានស្រាប់នៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលទៅក្នុង ការប្រព្រឹត្តទៅរបស់តុលាការនេះ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការ ពិពណ៌នេះទាំងមូលបង្ហាញពីមូលហេតុដ៏គួរឱ្យជឿជាក់ថា មានបុគ្គលបានជ្រៀតជ្រែក ឬ នៅតែបន្តជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការតទៅទៀត នោះអំណាចក្នុងការ ចាត់វិធានការណ៍គឺស្ថិតនៅលើអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូល។ ពិត ណាស់ ដោយសារតែបញ្ហាទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ភាពគ្មានឆន្ទៈច្បាស់ក្រឡែតរបស់ អង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់វិធានការ និងការបញ្ចប់នៃកិច្ចនីតិវិធីជំនុំជម្រះដែលនឹង ខិតជិតមកដល់នៅពេលឆាប់ៗខាងមុខនេះ អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវតែចាត់ វិធានការ។

## V. សេចក្ដីសន្និដ្ឋាន និងដំណោះស្រាយ

៣៣. ដោយសារហេតុផលខាងលើទាំងនេះ ផ្ទុយពីសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង សេចក្ដីដកស្រង់ចេញពីសៀវភៅ Lemonde ដែលបានភ្ជាប់មកក្នុងសំណើនេះបង្ហាញថា (i) រាជរដ្ឋាភិបាលកម្ពុជាបានជ្រៀតជ្រែក និងបន្តជ្រៀតជ្រែកក្នុងសំណុំរឿង០០២ នៅចំពោះមុខ អវតក និង(ii) ក្នុងកាលៈទេសៈនេះ វាមិនសមស្របឡើយក្នុងការទទួលយកសេចក្ដីសន្និដ្ឋាន របស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ។

៣៤. ដូច្នេះ មេធាវីការពារក្ដីសូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

ក.ទទួលយកជាភស្តុតាងនូវសេចក្តីដកស្រង់ចេញពីសៀវភៅ Lemonde ដែលបានភ្ជាប់មកជាមួយសំណើនេះ និង

ខ.ពិចារណាលើសេចក្តីដកស្រង់ទាំងនោះសម្រាប់គោលបំណងដែលបានបញ្ជាក់ក្នុងសំណើនេះ ។

**សហមេធាវីអន្តរជាតិលោក នួន ជា**

Victor KOPPE